មជ្ឈមណ្ឌលឯកសារកម្ពុជា

# ការរត់ប្រណាំងពេលវេលារបស់អង្គជំនុំជម្រះសាលាដំបូង ឆ្ពោះទៅពន្លឿនកិច្ចដំណើរការនីតិវិធីសវនាការ

*ថ្ងៃទី៦ ខែសីហា ឆ្នាំ២០១២*
*លឹម ជ័យទ័ត្ត, អ្នកសង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម*

នៅថ្ងៃទី៣ ខែសីហា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចេញអនុស្សរណៈមួយ ជូនដំណឹងដល់ភាគីអំពីវិធានការបន្ថែមក្នុងគោលបំណងពន្លឿនកិច្ចដំណើរការនីតិវិធីក្នុងការជំនុំជម្រះនៅក្នុងសវនាការនៃសំណុំរឿង០០២/០១ ។[១] នៅក្នុងអនុស្សរណៈនោះ អង្គជំនុំជម្រះសាលាដំបូងបានព្យាករណ៍ថា សវនាការលើកស្តុតាងក្នុងសំណុំរឿង០០២/០១ នឹងពុំទំនងជាអាចបញ្ចប់ឡើយរហូតដល់ឆ្នាំ២០១៤ បើផ្អែកតាមរយៈការវិវឌ្ឍនៃសវនាការនាពេលបច្ចុប្បន្ន ។[២] ប៉ុន្តែអង្គជំនុំជម្រះមានបំណងពន្លឿនកិច្ចដំណើរការនីតិវិធី ដោយបញ្ចប់សវនាការដេញដោលលើកស្តុតាងក្នុងសំណុំរឿង០០២/០១ នៅក្នុងឆ្នាំ២០១៣ ហើយនឹងចាប់ផ្តើមសំណុំរឿង០០២/០២ ភ្លាមៗ បន្ទាប់ពីការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលលើសំណុំរឿង០០២/០១ ។[៣]

អង្គជំនុំជម្រះមិនបានបញ្ជាក់ច្បាស់លាស់អំពីគោលបំណងនៃកិច្ចខិតខំប្រឹងប្រែងក្នុងការពន្លឿនកិច្ចដំណើរការនីតិវិធីនៅក្នុងអនុស្សរណៈដែលផ្ញើជូនភាគីនោះឡើយ ។ ប៉ុន្តែកិច្ចប្រឹងប្រែងនេះត្រូវបានមើលឃើញថា បណ្តាលមកពីបញ្ហាសុខភាពកាន់តែទ្រុឌទ្រោម និងវ័យកាន់តែជរារបស់ជនជាប់ចោទម្នាក់ៗ ដែលកំពុងក្លាយជាការគំរាមកំហែងដល់លទ្ធភាពនៃការចេញសាលក្រម ។

ជនជាប់ចោទទាំងបួនរូបក្នុងសំណុំរឿង០០២ ដែលមានវ័យចន្លោះពី៨០ទៅ៨៧ឆ្នាំ ភាគច្រើនបាននឹងកំពុងជួបប្រទះបញ្ហាសុខភាពធ្ងន់ធ្ងរ ។ ជនជាប់ចោទ អៀង សារី ត្រូវបានបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យជាបន្ទាន់កាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១២ ដោយសារបញ្ហារលាកទងសួត បន្ថែមលើរោគដែលមានពីមុនគឺជំងឺបេះដូង និងជំងឺសរសៃឈាម ហើយត្រូវក្រុមវេជ្ជបណ្ឌិតស្នើសុំអង្គជំនុំ

---

[១] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០១២ "ស្តីពីការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ ដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/០១ និងការអនុវត្តវិធានការបន្ថែមដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃសវនាការ ។"

[២] ដដែល ។ កថាខណ្ឌទី១ ។

[៣] ដដែល ។

ជម្រះអនុញ្ញាតឲ្យ អៀង សារី ចូលរួមសវនាការតាមរយៈប្រព័ន្ធសោតទស្សន៍ពីបន្ទប់រង់ចាំ ។[៤] ជនជាប់ចោទ នួន ជា កំពុងមានជំងឺទាក់ទងនឹងសរសៃឈាមបេះដូង ។ ជនជាប់ចោទ អៀង ធីរិទ្ធ អង្គជំនុំជម្រះសាលាដំបូងនឹងបើកសវនាការនាចុងខែសីហា ឆ្នាំ២០១២ ដើម្បីដឹងថា តើស្ថានភាពសម្បទា បញ្ញាស្មារតីរបស់ អៀង ធីរិទ្ធ វិវឌ្ឍន៍មករកភាពល្អប្រសើរ ឬវិវឌ្ឍន៍រកស្ថានភាពកាន់តែធ្ងន់ធ្ងរ ។[៥]

ដើម្បីពន្លឿនកិច្ចដំណើរការនីតិវិធីសវនាការ អង្គជំនុំជម្រះគ្រោងនឹងប្រើប្រាស់វិធានការមួយចំនួន ដូចជា កាត់បន្ថយការផ្តល់សក្ខីកម្មផ្ទាល់មាត់នៅក្នុងសវនាការរបស់សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ។ អង្គជំនុំជម្រះបានពន្យល់ថា *«សក្ខីកម្មរបស់អ្នកជំនាញមួយចំនួន នឹងពុំចាំបាច់ឡើយ ក្នុងអំឡុងសវនាការដំណាក់កាលដំបូង ដោយហេតុថា បន្ទាប់ពីមានដីកាបំបែកកិច្ចដំណើការនីតិវិធីរួចមក ភស្តុតាងដែលពួកគាត់នឹងផ្តល់នោះហាក់ដូចជាពុំពាក់ព័ន្ធសំខាន់ទៅនឹងសំណុំរឿង០០២/០១ឡើយ»*។[៦] អង្គជំនុំជម្រះក៏បានរកឃើញដែរថា សក្ខីកម្មមួយចំនួនមានលក្ខណៈត្រួតគ្នា ឬពុំមានភាពជាប់ពាក់ព័ន្ធផ្ទាល់នឹងអង្គហេតុនានាដែលបានដាក់បញ្ចូលទៅក្នុងសវនាការដំណាក់កាលដំបូងឡើយ ។[៧] ម្យ៉ាងវិញទៀត ក្នុងចំណោមសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីសរុបទាំងអស់ចំនួន១០៥៤នាក់ ដែលត្រូវបានស្នើសុំឲ្យកោះហៅក្នុងសំណុំរឿង០០២ ក្នុងចំណោមបុគ្គលទាំងនោះមានចំនួនតិចប៉ុណ្ណោះ ដែលអាចត្រូវបានអង្គជំនុំជម្រះស្តាប់សក្ខីកម្មក្នុងក្របខណ្ឌនៃការជំនុំជម្រះដោយយុត្តិធម៌ និងឆាប់រហ័ស ។[៨]

ក្រៅពីវិធានការខាងលើ ដើម្បីសម្រួលទាក់ទងនឹងការប្រើប្រាស់ចម្លើយរបស់សាក្សី អង្គជំនុំជម្រះនឹងអាចស្នើឲ្យសាក្សីធ្វើការបញ្ជាក់មុនពេលផ្តល់សក្ខីកម្មថា តើសាក្សីបានពិនិត្យមើលចម្លើយមុនៗរបស់ខ្លួនដែលបានសម្ភាសន៍នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ដែរឬយ៉ាងណា ហើយថាតើសាក្សីអះអាងថា ចម្លើយទាំងនោះពិតជាត្រឹមត្រូវឬយ៉ាងណា ។ បន្ទាប់មកអង្គជំនុំជម្រះ អាចនឹងសង្ខេបខ្លឹមសារនៃចម្លើយ ឬសក្ខីកម្មរបស់សាក្សីទាំងនោះនៅក្នុងសវនាការ ដើម្បីធានាថា ពុំមានការ

---

[៤] សូមមើលព្រឹត្តិបត្រ «សង្កេតការណ៍ ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម», ខែកក្កដា ឆ្នាំ២០១២ លេខទី១៣, ទំព័រ២ ។ អាចរកមើលបានតាមរយៈគេហទំព័រ http://www.d.dccam.org/Projects/ECCC_Trial_Observation/pdf/Observation_13.pdf

[៥] អាចរកមើលបានតាមរយៈគេហទំព័រ http://www.eccc.gov.kh/event/court-schedule/en/document/court/scheduling-reassessment-and-hearing-ieng-thirith-fitness-stand-trial

[៦] អនុស្សារណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០១២ «ស្តីពីការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ ដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/០១ និងការអនុវត្តវិធានការបន្ថែមដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃសវនាការ ។» កថាខណ្ឌទី៤ ។

[៧] ដដែល ។ កថាខណ្ឌទី៥ ។

[៨] ដដែល ។ កថាខណ្ឌទី១២ ។

ខ្ជះខ្ជាយពេលវេលាដ៏មានតម្លៃនៅពេលសវនាការ ដោយសារភាពច្រំដែលឥតប្រយោជន៍នៃចម្លើយរបស់សាក្សីដែលបានស្បថ និងបានផ្តល់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេតរួចហើយ ។[៩]

អង្គជំនុំជម្រះក៏មាននីតិវិធានការពន្លឿនការសួរដេញដោលរបស់ភាគី ដែលធ្វើឡើងនៅអំឡុងពេលនៃការចោទសួរលើ សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដោយលើកទឹកចិត្តឲ្យភាគីទាំងអស់ពិចារណាអំពីការចាត់តាំងមេធាវីចំនួន១រូប (មិនថាមេធាវីជាតិ ឬមេធាវីអន្តរជាតិ) ដើម្បីដឹកនាំការសួរដេញដោលនៅក្នុងសវនាការលើបុគ្គលម្នាក់ៗ ឬដើម្បីអនុវត្តវិធានការផ្សេងៗដើម្បីបញ្ចៀសភាពច្រំដែល ។ អង្គជំនុំជម្រះបានពន្យល់ថា ភាគីខ្លះមានមេធាវីចំនួន២រូប (មេធាវីជាតិមួយរូប និងមេធាវីអន្តរជាតិមួយរូប) និងគាប់ជួនពេលខ្លះមានមេធាវីចំនួន៣រូប សួរដេញដោលសាក្សី អ្នកជំនាញ ឬដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗនៅក្នុងសវនាការ ។ បន្ថែមពីលើនេះ អង្គជំនុំជម្រះបានស្នើសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញាសហការគ្នាដើម្បីបញ្ចៀសការសួរសំណួរច្រំដែលនៅសវនាការ ។[១០]

ពាក់ព័ន្ធនឹងការចូលរួមរបស់ជនជាប់ចោទ អង្គជំនុំជម្រះគ្រោងនឹងធ្វើសវនាការនៅថ្ងៃច័ន្ទ ថ្ងៃអង្គារ ថ្ងៃព្រហស្បតិ៍ និងថ្ងៃសុក្រ (ដោយទុកថ្ងៃពុធ សម្រាប់ការពិភាក្សាសម្រេចរបស់ចៅក្រម) ដើម្បីកាត់បន្ថយរយៈពេលដែលជនជាប់ចោទត្រូវចូលរួមសវនាការជាប់ៗគ្នាជារៀងរាល់ថ្ងៃ ។ ប៉ុន្តែការរៀបចំបែបនេះ អង្គជំនុំជម្រះនឹងស្នើក្រុមមេធាវីការពារក្តីបញ្ជាក់ ថាតើខ្លួនយល់ថា ការរៀបចំដូច្នេះទំនងជាផ្តល់ប្រយោជន៍ដល់កូនក្តីរបស់ខ្លួនដែរ ឬយ៉ាងណា ។[១១] គួរកត់សម្គាល់ថា កាលវិភាគដែលអង្គជំនុំជម្រះធ្វើសវនាការក្នុងសប្តាហ៍នីមួយៗនាពេលបច្ចុប្បន្ន គឺចាប់ពីថ្ងៃច័ន្ទ រហូតដល់ថ្ងៃព្រហស្បតិ៍ ។

ស្របពេលជាមួយនឹងកិច្ចប្រឹងប្រែងក្នុងការពន្លឿនកិច្ចដំណើរការនីតិវិធីសវនាការក្នុងសំណុំរឿង ០០២/០១ របស់អង្គជំនុំជម្រះសាលាដំបូង សហព្រះរាជអាជ្ញាបានស្នើសុំឲ្យមានការពង្រីកវិសាលភាពនៃការចោទប្រកាន់នានានៅក្នុងសំណុំរឿង០០២/០១ ជាពិសេសការស្នើសុំដាក់ទីតាំងឧក្រិដ្ឋកម្មបន្ថែមចំនួនពកន្លែង និងការចោទប្រកាន់លើអង្គហេតុពីក្នុងដីកាដំណោះស្រាយ ។[១២] អង្គជំនុំជម្រះបានលើកឡើងថា៖

---

[៩] ដដែល ។ កថាខណ្ឌទី៧ ។

[១០] ដដែល ។ កថាខណ្ឌទី៨ ។

[១១] ដដែល ។ កថាខណ្ឌទី៩ ។

[១២] អនុស្សារណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី សំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំពង្រីកវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង០០២/០១ (ឯកសារ E163) ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០១២ ។

*ថ្មីបើអង្គជំនុំជម្រះសាលាដំបូងមានក្តីបារម្ភពាក់ព័ន្ធទៅនឹងល្បឿននៃការជំនុំជម្រះក្តីក៏ដោយ សហព្រះរាជអាជ្ញាបានជំរុញម្តងហើយម្តងទៀតឲ្យមានការលើកឡើង អំពីការពង្រីកវិសាលភាពនៃការចោទប្រកាន់នានានៅក្នុងសំណុំរឿង០០២/០១ ។ ទោះបីជាកិច្ចខិតខំប្រឹងប្រែងរបស់អង្គជំនុំជម្រះសាលាដំបូង មកទល់នឹងពេលនេះ គឺជាការយកចិត្តទុកដាក់ដើម្បីធានាឲ្យការជំនុំជម្រះកាន់តែមានប្រសិទ្ធភាពក៏ដោយ អង្គជំនុំជម្រះក៏បានលះបង់ពេលវេលា និងធនធានយ៉ាងធំធេងដើម្បីធ្វើការវាយតម្លៃលើផលប៉ះពាល់នៃការយល់ព្រមតាមសំណើរបស់សហព្រះរាជអាជ្ញា ក្នុងការស្នើសុំពង្រីកវិសាលភាពនៃសំណុំរឿង០០២/០១ ដូចមានក្នុងឯកសារ E163 ។*[១៣]

អង្គជំនុំជម្រះក៏បានបង្ហាញការព្រួយបារម្ភថា នៅក្នុងករណីសំណើសុំរបស់សហព្រះរាជអាជ្ញា ដើម្បីពង្រីកវិសាលភាពនៃសំណុំរឿង០០២/០១ ត្រូវបានឯកភាពដោយអង្គជំនុំជម្រះ កិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង០០២/០១ នឹងអាចត្រូវពន្យាពេល ។ ដោយសារសាក្សីជាច្រើននាក់ដែលអាចមានការពាក់ព័ន្ធនឹងការពង្រីកវិសាលភាពដែលបានស្នើសុំនោះ មិនទាន់ត្រូវបានស្តាប់ចម្លើយនៅចំពោះមុខអង្គជំនុំជម្រះនៅឡើយ ។[១៤]

ដើម្បីជៀសវាងពីហានិភ័យដែលនាំឲ្យមានការពន្យាពេលនៃកិច្ចដំណើរការនីតិវិធី ដោយសារការពង្រីកវិសាលភាពនៃសំណុំរឿង០០២ អង្គជំនុំជម្រះបានស្នើសហព្រះរាជអាជ្ញាធ្វើការបង្ហាញថា តើផលប្រយោជន៍ដែលខ្លួនគិតថាអាចទទួលបានពីការពង្រីកវិសាលភាពដែលបានស្នើសុំនោះ មានសារៈសំខាន់ជាងហានិភ័យនានាដែលកើតឡើង ដោយសារការអូសបន្លាយពេលកិច្ចដំណើរការនីតិវិធីសវនាការដែរឬយ៉ាងណា ។ ជាពិសេសនៅពេលគិតពីផលប្រយោជន៍របស់ជនរងគ្រោះនៃឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហម ធៀបទៅនឹងលទ្ធភាពនៃការចេញសាលក្រមឲ្យបានឆាប់រហ័ស ។

ការព្យាយាមរបស់អង្គជំនុំជម្រះដើម្បីពន្លឿនកិច្ចដំណើរការនីតិវិធីឲ្យបានឆាប់រហ័ស អាចនឹងត្រូវប្រឈមជាមួយនឹងបញ្ហាមួយចំនួន ដែលនាំឲ្យមានការពន្យាពេលក្នុងការចេញសាលក្រមសម្រាប់សវនាការដំណាក់កាលដំបូងនេះ ប្រសិនបើសំណើសុំរបស់សហព្រះរាជអាជ្ញាក្នុងការពង្រីកវិសាលភាពនៃសវនាការសំណុំរឿង០០២/០១ត្រូវបានឯកភាពទទួលយកដោយអង្គជំនុំជម្រះ ។ នេះគឺជាកិច្ចការ

[១៣] អនុសារណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០១២ "ស្តីពីការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ ដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង០០២/០១ និងការអនុវត្តវិធានការបន្ថែមដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃសវនាការ ។" កថាខណ្ឌទី១៣ ។

[១៤] ដដែល ។ កថាខណ្ឌទី១៤ ។

ដ៏លំបាកដែលអង្គជំនុំជម្រះចាំបាច់ត្រូវដោះស្រាយ និងត្រូវជ្រើសរើសថា តើគួរសម្រេចពង្រីកវិសាលភាពនៃសំណុំរឿងទៅតាមសំណើសុំរបស់សហព្រះរាជអាជ្ញា? ឬត្រូវគិតអំពីសិទ្ធិទទួលបានការជំនុំជម្រះដោយឆាប់រហ័សរបស់ជនជាប់ចោទដែលមានអាយុកាន់តែជរា ដើម្បីធ្វើការពន្លឿនកិច្ចដំណើរការនីតិវិធី?

សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងការពង្រីកវិសាលភាពនៃសំណុំរឿង០០២/០១អាចនឹងត្រូវសម្រេច នៅក្រោយកិច្ចប្រជុំរៀបចំសវនាការដែលរៀបចំឡើងដោយអង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២ ។

-ចប់-